# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣៤ អនក្រ.បក

## អនុក្រឹត្យ
## ស្ដីពី
## ការកែសម្រួលប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការស៊ីវិល និង ប្រាក់កំរៃគរុកោសល្យក្នុងវិស័យអប់រំ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្ដីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្ដីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការ

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

## សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

អនុក្រឹត្យនេះ មានគោលដៅបំពេញបន្ថែមព្រះរាជក្រឹត្យ ស្ដីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្ស ដូចមានចែងក្នុងជំពូកទី២ ស្ដីពីប្រាក់បំណាច់មុខងារ ។

**មាត្រា ២.-**

អនុក្រឹត្យនេះ កំណត់ការកែប្រែប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការដែលមានមុខតំណែងជា ប្រធាននាយកដ្ឋាន អភិបាលរងខេត្ត-ក្រុង អធិការថ្នាក់កណ្តាល ព្រឹទ្ធបុរសមហាវិទ្យាល័យ អភិបាលស្រុក-ខណ្ឌ ហើយដែលស្ថិតនៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួង-ស្ថាប័ន និងកំណត់បន្ថែម ប្រាក់កំរៃគរុកោសល្យរបស់មន្ត្រីរាជការ ក្នុងវិស័យអប់រំ ។

## ជំពូកទី ២
## ប្រាក់បំណាច់មុខងារ

**មាត្រា ៣.-**

មន្ត្រីរាជការស៊ីវិល ដែលមានមុខតំណែងជា ប្រធាននាយកដ្ឋាន អភិបាលរងខេត្ត-ក្រុង អធិការថ្នាក់កណ្តាល ព្រឹទ្ធបុរសមហាវិទ្យាល័យ អភិបាលស្រុក-ខណ្ឌ ហើយដែលស្ថិតនៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួង-ស្ថាប័នថ្នាក់កណ្តាល ត្រូវបានទទួលប្រាក់បំណាច់មុខងារប្រចាំខែ ដូចមានចែងនៅក្នុងតារាងខាងក្រោមនេះ :

| ល.រ | មុខងារ | កាំរិត ទី៥ | កាំរិត ទី៤ | កាំរិត ទី៣ | កាំរិត ទី២ | កាំរិត ទី១ |
|---|---|---|---|---|---|---|
| ១ | ប្រធាននាយកដ្ឋាន | ៦២០ ០០០ ៛ | ៦៥៨ ០០០ ៛ | ៦៩៨ ០០០ ៛ | ៧៤១ ០០០ ៛ | ៧៨៦ ០០០ ៛ |
| ២ | អភិបាលរង ខេត្ត-ក្រុង | ៦១៥ ០០០ ៛ | ៦៥៣ ០០០ ៛ | ៦៩៣ ០០០ ៛ | ៧៣៦ ០០០ ៛ | ៧៨១ ០០០ ៛ |
| ៣ | អធិការថ្នាក់កណ្តាល | ៦១០ ០០០ ៛ | ៦៤៨ ០០០ ៛ | ៦៨៨ ០០០ ៛ | ៧៣១ ០០០ ៛ | ៧៧៦ ០០០ ៛ |
| ៤ | ព្រឹទ្ធបុរសមហាវិទ្យាល័យ | ៦០៥ ០០០ ៛ | ៦៤៣ ០០០ ៛ | ៦៨៣ ០០០ ៛ | ៧២៦ ០០០ ៛ | ៧៧១ ០០០ ៛ |
| ៥ | អភិបាល ស្រុក-ខណ្ឌ | ៥០០ ០០០ ៛ | ៥៣៨ ០០០ ៛ | ៥៧៨ ០០០ ៛ | ៦២១ ០០០ ៛ | ៦៦៦ ០០០ ៛ |

**មាត្រា ៤.-**

ប្រធានអង្គភាព ដែលមានរចនាសម្ព័ន្ធក្នុងក្រសួង-ស្ថាប័ន និងស្មើនាយកដ្ឋាន ត្រូវទទួលបានប្រាក់បំណាច់មុខងារជាប្រធាននាយកដ្ឋាន ដូចមានចែងនៅក្នុងមាត្រា ៣ ។

## ជំពូកទី ៣
## ប្រាក់កំរៃគរុកោសល្យ

**មាត្រា ៥.-**

ប្រាក់កំរៃគរុកោសល្យ គឺជាប្រាក់បន្ថែមលើប្រាក់បំណាច់មុខងារប្រចាំខែ ដែលត្រូវផ្តល់ជូនមន្ត្រីរាជការក្នុងវិស័យអប់រំ ហើយដែលបានឆ្លងកាត់ វគ្គបណ្តុះបណ្តាលគរុកោសល្យ ។